# TTB -0026

## សេចក្តីផ្តើម

**ក៖** អស់លោកលោកស្រីប្រិយមិត្តកំពុងស្តាប់កម្មវិធីសិក្សាតាមប្រពន្ធ័ព្រះគម្ពី  កម្មវិធីយើងខ្ញុំមានបិតិសោមន្សយ៉ាងខ្លាំងដែលលោកអ្នកបានចំណាយពេលវេលាដ៏មានតំលៃស្តាប់កម្មវិធីរបស់យើងខ្ញុំកម្មវិធីសិក្សាតាមប្រពន្ធ័ព្រះគម្ពីផ្តល់សារះប្រយោជន៏ដល់លោកអ្នកអោយស្គាល់ព្រះជាម្ចាស់និងលូតលាស់ខាងជំនឿរហូតដល់លោកអ្នកអាចបង្កើតផលផ្លែជាប់លាប់ថ្វាយព្រះអង្គម្ចាស់បានយើងខ្ញុំសង្ឃឹមថាកម្មវិធីថ្ងៃនេះពិតជានាំមកនូវព្រះពរណាមួយដល់លោកអ្នកជាមិនខាន។

**ខ៖** លោក លោកស្រីនិងប្រិយមិត្តអ្នកស្តាប់ជាទីមេត្រី ក្នុងវគ្គសិក្សាកន្លងទៅយើងបានសិក្សាអំពីសេចក្តីពិតនានាដូចបានសំដែងនៅក្នុងព្រះគម្ពីប៊ីបរួចមកហើយយើងខ្ញុំសូមអញ្ជើញអស់លោកអ្នក សិក្សាមេរៀនរបស់យើងជាបន្តទៅទៀត នៅថ្ងៃនេះ យើងសិក្សាកាណ្ឌលោកុប្បត្តិ១២:៤-១២ ឯសេចក្តីដែលមានបរិយាយនៅក្នុងថ្ងៃនេះ គឺជំនឿវង្សរបស់ពូជមនុស្សជាតិ ចាប់ពីលោកសឹមដល់លោកអាប្រាហាំ។

**គ៖** ចាំអស់លោកអ្នកបងប្អូនដើម្បីអោយកាន់តែយល់ច្បាស់នៅមេរៀបរបស់យើងនៅថ្ងៃនេះ សូមបានចូលរួមសណ្តាប់ដូចតទៅ---



Page **1** of **13**

# លោកុប្បត្តិ ១២ : ៣-១២

ហេតុអ្វីបានជាព្រះជាម្ចាស់មិនចង់អោយលោកអ័ប្រាហាំយកឪពុកទៅជាមួយ?ចម្លើយ នេះឃើញមាននៅក្នុងកំណ្ឌគម្ពីរយ៉ូស្វេ។ពួកព្ធយុកោឯងរាល់គ្នាពីដើមបាននៅខាងនាយទន្លេ គឺថេរ៉ាជាឪពុកអ័ប្រាហាំនឹងណាឃរគេក៏បានគោរពប្រតិបត្តិដល់ព្រះដ៏ទៃដែរ”(យ៉ូស្វេ២៤:២)។“គេក៏បានគោរពប្រតិបត្តិដល់ព្រះដ៏ទៃដែរ” ត្រង់នេះស បញ្ជាក់ថា គ្រួសារលោកអ័ប្រាហាំ រួមទាំងលោកអ័ប្រាហាំផ្ទាល់ខ្លួនផងដែរធ្លាប់បានគោរពតាមរូបព្រះដ៏ទៃកន្លងមក។លោកីយ៍សម័យនោះលង់ខ្លួនធ្វើអាក្រក់ដាច់ពីព្រះជាម្ចាស់ដល់ថ្នាក់នោះទៅហើយ។ប៉ុន្តែទោះបីជាបែបនោះក៏ដោយក៏ព្រះអង្គមិនបណ្តោតបណ្តាយអោយមនុស្សលោកដែលទ្រង់បង្កើតមកនោះ ធ្វើតាមតែអំពើចិត្តខ្លួននោះឡើយ។ទ្រង់បានត្រាស់ហៅលោកអ័ប្រាហាំ ដើម្បីរក្សាពូជមនុស្សលោកអោយគង់វង់តរៀងរហូតមក។ទន្ទឹមនឹងការត្រាស់ហៅលោកអ័ប្រាហាំអោយរក្សាពូជមនុស្សលោកព្រះជាម្ចាស់អាចធ្វើវិធីផ្សេងមួយទៀតក៏បាន។ឯវិធីនោះគឺព្រះអង្គបំផ្លាញមនុស្សជាតិទាំងមូលអោយក្លាយទៅជាផង់ធូលីដីរួចហើយយកធូលីដីនោះមកសូនធ្វើជាមនុស្សសារជាថ្មី។ប៉ុន្តែព្រះគម្ពីរបញ្ជាក់ថាព្រះជាម្ចាស់មិនបានធ្វើតាមវិធីខាងក្រោយនេះឡើយ។បើប្រសិនណាជាព្រះជាម្ចាស់បែរជាធ្វើយ៉ាងដូច្នេះវិញមែនរូបខ្ញុំផ្ទាល់មិនអាចបានមកអធិប្បាយព្រះបន្ទូលអោយបងប្អូនស្តាប់នៅថ្ងៃនេះទេពីព្រោះខ្ញុំក៏ជាមនុស្សមានបាបដូចជាបងប្អូនរាល់គ្នាដែរ។តាមពិតទៅមនុស្សមានបាបរាល់រូបសមនឹងទទួលទោសដែលព្រះជាម្ចាស់ដាក់មកប្រាកដហើយ។ប៉ុន្តែយើងអរព្រះគុណដល់ព្រះជាម្ចាស់ដ្បិតព្រះអង្គមានក្តីមេត្តាករុណាពោរពេញទៅដោយព្រះគុណហើយទ្រង់បានសង្គ្រោះមនុស្សមានបាបគ្រប់រូបអោយតែមនុស្សនោះបែរទៅរកទ្រង់។ឥឡូវនេះយើងបន្តសិក្សាព្រះគម្ពីរទៅទៀត ហើយយើងនៅតែប្រើឈ្មោះអាប់រ៉ាមរហូតទំរាំដល់ជំពូកទី១៧ ដែលព្រះជាម្ចាស់បានដូរឈ្មោះលោកទៅជាអ័ប្រាហាំ វិញ។



Page **2** of **13**

**អាប់រ៉ាមក៏ចេញទៅដូចជាព្រះយេហូវ៉ាបានបង្គាប់ ឡុតក៏ទៅជា មួយដែរ កាលអាប់រ៉ាមចេញពីខារ៉ានទៅ នោះគាត់អាយុ បាន៧៥ឆ្នាំហើយ ៖លោកុ៖១២ː៤៖។**

“អាប់រ៉ាមក៏ចេញទៅដូចជាព្រះយេហូវ៉ាបានបង្គាប់”។ក្នុងខណៈនេះលោកបានចេញដំណើរតាមសេចក្ដីបង្គាប់របស់ព្រះ ឆ្ពោះទៅរស់នៅឯទឹកដីកាណាន។ “ឡុត ក៏ទៅជាមួយដែរ” អុញនោ៎ះ៖ ឥឡូវនេះឃើញថាលោកមិនបានស្ដាប់បង្គាប់ដល់ព្រះជាម្ចាស់ក្នុងករណីយ៍មួយទៀតហើយ ពោលគឺលោកបានសណ្ដោងរយោងក្មួយរបស់ លោកម្នាក់ឈ្មោះឡុតទៅជាមួយដែរ។

**ក៏យកសារ៉ាយជាប្រពន្ធនិងឡុតជាក្មួយ ព្រមទាំងរបស់ទ្រព្យទាំងប៉ុន្មាន ដែលបានប្រមូលទុក និងមនុស្សទាំងអស់ដែលបាន កាលនៅខារ៉ានផង នាំគ្នាចេញពីទីនោះ ដើម្បីទៅឯស្រុក កាណាន ក៏ចូលទៅក្នុងស្រុកនោះ ៖លោកុ៖១២ː៥៖។**

អាប់រ៉ាមបានយកភរិយាលោកឈ្មោះសារ៉ាយទៅជាមួយដែរហើយបើតាមខ្ញុំយល់ការដែលកសម្រេចយកភរិយាទៅជាមួយនេះពិតជាល្អរកអ្វីប្រៀបផ្ទឹមមិនបានទេ។កាលណាព្រះជាម្ចាស់ត្រាស់ហៅប្ដីរបស់ភរិយាណាមួយព្រះអង្គតែងតែត្រាស់ហៅប្រពន្ធទៅមួយជាដាច់ខាត។ព្រះអង្គមិនដែលត្រាស់ហៅអោយប្ដីទៅបម្រើ ព្រះអង្គតែម្នាក់ឯងចោលប្រពន្ធ ឬក៏ហៅប្រពន្ធដោយមិនត្រាស់ហៅប្ដីនោះទេ។ព្រះជា ម្ចាស់ត្រាស់ហៅទាំងពីរនាក់ប្ដីប្រពន្ធ ពីព្រោះទ្រង់មិនចង់អោយអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរមានការបែកបាក់ឡើយ។ព្រះអង្គមិនត្រាស់ហៅប្ដីប្រពន្ធទាស់ទទឹងនឹងគោលការណ៍អាពា



Page **3** of **13**

ហ៍ពិពាហ៍ ដែលទ្រង់ចែកជាកេរ្តិ៍មរតកមកអោយមនុស្សលោកនោះ ឡើយ។ មានបុរសម្នាក់យល់ថាព្រះត្រាស់ហៅខ្លួនអោយទៅបម្រើព្រះអង្គ។ពេលក្រុមគ្រូគង្វាលមួយក្រុមសួរគាត់ថាហេតុអ្វីមិនយកប្រពន្ធទៅជាមួយផង គាត់ឆ្លើយឡើងថា "ប្រពន្ធខ្ញុំបំផ្លាញការងារព្រះអង្គដែលខ្ញុំបម្រើនោះជានិច្ច។" ខ្ញុំជឿជាក់ថា ព្រះជាម្ចាស់ មិនបានត្រាស់ហៅបុរសម្នាក់នេះអោយទៅបម្រើព្រះអង្គតែម្នាក់ឯងទេ។ លោកអ័ប្រាហាំស្តាប់តាមការត្រាស់ហៅរបស់ព្រះ បានជាលោកយកភរិយាលោកទៅជាមួយ ហើយភិរិយានេះជាកិរិយាប្រសើរជាទីបំផុត។"និងឡុតជាក្មួយព្រមទាំងរបស់ទ្រព្យទាំងប៉ុន្មានដែលបានប្រមូលទុក នឹង មនុស្សទាំងអស់ដែលបាន កាលនៅខារ៉ានផង"។ រយៈពេលដែលអាប់រ៉ាមស្នាក់នៅក្នុងទីក្រុងខារ៉ានគឺជាថេរៈវេលាដែលបង្អាក់ព្រះពរពីព្រះជាម្ចាស់ដែលទ្រង់ថានឹងប្រទានអោយមកលោក។ព្រះជាម្ចាស់មិនដែលបើកសម្តែងអោយលោកឃើញទៀតទេទាល់តែដល់វេលាដែលលោកធ្វើដំណើរទៅដល់ទឹកដីប៉ាឡេស្ទីន ដែលជាកន្លែងលោក រស់នៅឆ្ងាយពីសាច់ញាតិជិតដិតរបស់លោក ហើយមានតែក្មួយលោកម្នាក់ឈ្មោះឡុតតែ ប៉ុណ្ណោះ។

"ក៏ចូលទៅក្នុងស្រុកនោះ" ឥឡូវនេះសូមស្តាប់សេចក្តីដែលបានចែងនៅក្នុង ខ.៦។

**អាប់រ៉ាមគាត់ដើរកាត់ស្រុកទៅត្រឹមដើមម៉ៃសាក់ របស់ម៉ូរេ នៅ កន្លែង១ឈ្មោះស៊ីគែម ដែលនៅវេលានោះ សាសន៍កាណាន នៅស្រុកនោះដែរ (លោកុ ១២:៦)។**

ត្រង់នេះយើងឃើញមានកំណាត់ហេតុដែលបញ្ជាក់ថា ពួកសាសន៍កាណាន នេះជាកូនចៅរបស់កាណានដែលត្រូវជាកូនរបស់ហាំផ្ទាល់។ នៅចំណុចនេះ ខ្ញុំចង់ បន្ថែមសេចក្តីមួយដែលសំខាន់ដែលយើងទាំងអស់គ្នាចាំបាច់ត្រូវតែដឹង។ មានមនុស្ស ជាច្រើនណាស់ ដែលប្រកាន់ជំហរថាអាប់រ៉ាមធ្វើដំណើរចាកចេញពីទីក្រុងនៃប្រទេស ខាល់ដេ ពីព្រោះមនុស្សដែលរស់នៅក្នុងទីក្រុងនោះសុទ្ធតែជាមនុស្សមានអាកប្បកិរិយាសហាវយង់ឃ្នង។អ្នកទាំងនោះអះអាងថាលោកអ័ប្រាហាំព្រមចេញ



Page **4** of **13**

ពីទឹកដីអាក្រក់នេះដើម្បីទៅរកទឹកដីមួយទៀត ដែលពោរពេញទៅដោយផ្លែឈើ មានទឹកទំពាំងបាយជូរ មានទឹកដោះហើយនឹងមានទឹកឃ្មុំផងដែរពោលគឺជាទឹកដីដែលស្រស់ថ្លា។គេថាលោកអ័ប្រាហាំត្រូវការ កន្លែងល្អដើម្បីនឹងរស់នៅ។ ខ្ញុំសុំកុំអោយលោកអ្នកបងប្អូនយល់ ច្រឡំយ៉ាងដូច្នេះអោយសោះ។ ព្រះគម្ពីរមិនបានចែងថាទឹកដីកាណានជាទឹកដីស្រស់ថ្លានោះទេ។តាមការស្រាវជ្រាវរបស់ពួកបុរាណវិទូ គេបានរកឃើញថាទីក្រុងអ៊ើរនៅក្នុងប្រទេសខាល់ដេនេះនៅសម័យដែលលោកអ័ប្រាហាំរស់នៅមាន អារ្យធម៌ខ្ពង់ខ្ពស់ ខ្លាំងណាស់។ សម័យនោះលោកអាប់រ៉ាមនិងនាងសារ៉ាយប្រហែលជាមានទឹកក្តៅប្រើ នៅក្នុងផ្ទះរបស់ខ្លួនផងក៏មិនដឹង។ទីក្រុងនោះជាទីក្រុងដែលលូតលាស់ហើយសម្បូររុងរឿងយ៉ាង អស្ចារ្យ។ តែទោះបីជារុងរឿងយ៉ាងណាក៏ដោយ អាប់រ៉ាមបានចាកចោល កន្លែងសុខសាន្តរបស់លោក ដើម្បីធ្វើដំណើរទៅទឹកដីកាណាន "ដែលនៅវេលានោះ សាសន៍កាណាននៅស្រុកនោះដែរ"។ សាសន៍កាណានមិនមែនជាសាសន៍ដែលមានអារ្យធម៌ខ្ពង់ខ្ពស់ទេសាសន៍នោះមានលក្ខណៈដូច មនុស្សព្រៃហើយមានកិរិយាទមិឡផងដែរបើសិនជាសម័យនោះមានទមិឡមែន។គោលបំណងរបស់ អាប់រ៉ាមដែល ធ្វើដំណើរទៅទឹកដីកាណាននោះ មិនមែនជាគោលបំណងដែលលោកទៅរកទឹកដីដែល ប្រសើរជាងនោះទេ។លោកព្រមចាកចោលទីក្រុងរបស់លោកយ៉ាងសុខសាន្តមករស់នៅទឹកដីដែល ពោរពេញទៅដោយអំពើបាបនេះគឺលោកស្ម័គ្រធ្វើតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់តែមួយមុខ ប៉ុណ្ណោះ។ឥឡូវនេះពេលដែលលោកអ័ប្រាហាំស្តាប់បង្គាប់ដល់ព្រះជាម្ចាស់ហើយសូមកត់ចំណាំថា មានការជាច្រើនដែលកើតឡើង។

**ព្រះយេហូវ៉ាទ្រង់លេចមកអោយអាប់រ៉ាមឃើញហើយមានបន្ទូលថា អញនឹងអោយស្រុកនេះដល់ពូជឯងរួចនៅទីនោះគាត់ក៏ ស្អាងអាសនា១ថ្វាយព្រះយេហូវ៉ា ដែលទ្រង់លេចមកអោយឃើញ នោះ ៖លោកុ៖១២០:៧៖។**



Page 5 of 13

នៅពេលដែលលោកបានធ្វើដំណើរមកដល់ទឹកដីកាណានហើយលោកក៏សង់អាសនាមួយថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់ដ្បិតពេលនោះព្រះអង្គបានអនុញ្ញាតអោយ លោកឃើញទ្រង់ជាលើកទីពីរ។ ក្នុងថេរៈវេលាដែលលោកសម្រាកនៅខារ៉ានដែលប្រែថាកន្លែងអែរអង់ព្រះជាម្ចាស់មិនបានបើកសម្តែងអង្គទ្រង់អោយលោកឃើញសោះ ឡើយ។

លោកអ្នកបងប្អូនឃើញហើយ ត្រង់ចំណុចនេះថា មូលហេតុមួយដែលបងប្អូន ហើយនិងខ្ញុំមិនបានទទួលពរពីព្រះជាម្ចាស់ពីព្រោះយើងទាំងអស់គ្នាមិនបានរស់ក្នុងជីវិតមួយដែលយកព្រះជាម្ចាស់ធ្វើជាខ្នាតសម្រាប់យើងទាំងអស់គ្នា។បើប្រសិនណាជាយើងស្តាប់បង្គាប់ដល់ព្រះជាម្ចាស់អោយអស់ពីចិត្តរបស់យើងនោះយើងពិតជាមានព្រះពរថែមទៀតនៅក្នុងជីវិតរបស់យើង។យើងឃើញនៅក្នុងបទពិសោធន៍របស់លោក អ័ប្រាហាំនេះ ព្រះជាម្ចាស់មិនបើកសម្តែងអង្គទ្រង់អោយលោកឃើញទៀតទេ លុះត្រា ដល់ពេលដែលលោកបានចាប់ផ្តើមស្តាប់បង្គាប់ព្រះអង្គ ហើយរស់នៅតាមខ្នាតដែលព្រះជាម្ចាស់ដាក់មកសម្រាប់រូបលោក។ប៉ុន្តែមកទល់ពេលនេះទើបព្រះជាម្ចាស់បានបើកសម្តែងអោយលោកឃើញម្តងទៀត។លោកបានជួបជាមួយព្រះអង្គហើយលោកបានសាងអាសនាមួយដែលល្អបណ្តាច់។

**គាត់ចេញពីទីនោះ ទៅឯភ្នំនៅខាងកើតបេត-អែល ក៏ដំឡើង ត្រសាលនៅឯណោះ មានបេតអែលនៅជាខាងលិចនិងអៃយនៅខាងកើតហើយស្អាងអាសនា១ថ្វាយព្រះយេហូវ៉ានៅទីនោះ ដែរ រួចអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា ៖លោកុ៖១២ៈ៨៕។**



Page **6** of **13**

ពេលដែលលោកធ្វើដំណើរទៅដល់ស្រុកនោះហើយ អ័ប្រាហាំបានធ្វើការពីរ យ៉ាង។ ទី១គឺលោកបានដំឡើងត្រសាល។ការដំឡើងត្រសាលនេះប្រៀបដូចជាទៅដល់ស្រុកថ្មីមួយក៏ទិញផ្ទះនៅទីនោះ។ លោក "ដំឡើងត្រសាល" ហើយក្នុងត្រសាល នេះឯងជាកន្លែងដែលលោករស់នៅ។ ទី២ គឺលោកស្អាងអាសនាមួយសម្រាប់ដុតដង្វាយថ្វាយព្រះយេហូវ៉ា។អាសនានេះជាទីបន្ទាល់ដែលសម្តែងពីព្រះជាម្ចាស់បានបើក សម្តែងអោយលោកឃើញ ហើយទីណាដែលលោកធ្វើដំណើរទៅដល់ លោកតែងតែ បន្សល់ស្នាមទីបន្ទាល់យ៉ាងដូច្នោះជានិច្ចជាកាល។ មិត្តសម្លាញ់អើយ តើនៅក្នុងជីវិតរបស់លោកអ្នកតើមានភិនភាគណាម៉្យាងដែលជាទីបន្ទាល់ប្រាប់ដល់អ្នកផងទាំងពួងថាលោកអ្នកជាអ្នកស្តាប់បង្គាប់ព្រះ?ដើម្បីធ្វើជាទីបន្ទាល់លោកអ្នកមិនចាំបាច់យកឈើឆ្កាងទៅឆ្លាក់បន្ទុបនៅលើខ្លោងទ្វារនៅមុខផ្ទះទេក៏មិនបាច់យកផ្លាកបិទនៅកន្ទុយឡានប្រាប់ថា"ព្រះយេស៊ូវសង្គ្រោះ"រួចហើយបើកឡានមិនស្គាល់ឆ្វេងមិនស្គាល់ស្តាំដូចជាមនុស្សខ្លះធ្លាប់ធ្វើនោះទេ។គ្រីស្ទបរិស័ទខ្លះចង់សម្គាល់ភិនភាគថាខ្លួនជាអ្នក ស្រឡាញ់ព្រះយេស៊ូវគ្រីស្ទណាស់ រហូតធ្វើក្រវិលឈើឆ្កាងពីរពាក់នៅនឹងត្រចៀកខ្លួនមួយម្ខាង។ មាននារីម្នាក់ពាក់ឈើឆ្កាងនៅនឹងត្រចៀកខ្លួន។ ពេលអង្គុយទទួលអាហារ នៅផ្ទះលក់បាយ ខ្ញុំក៏រើកន្លែងទៅអង្គុយជិតនាងប្រាថ្នាចង់ដឹងថាហេតុអ្វីបានជាសព្វថ្ងៃនេះនារីៗចូលចិត្តពាក់ឈើឆ្កាងនៅនឹងត្រចៀកខ្លួន ទោះបីខ្លួនមិនជឿដល់ព្រះយេស៊ូវក៏ ដោយ។ បន្ទាប់ពីណែនាំអោយស្គាល់ឈ្មោះខ្ញុំ ហើយខ្ញុំក៏ចាប់ផ្តើមសួរសុខទុក្ខដល់មិត្តភ័ក្តិរបស់នាងទាំងពីររូប។រួចហើយខ្ញុំប្រាប់នាងដែលពាក់ឈើឆ្កាងនៅនឹងត្រចៀកពីឈ្មោះខ្ញុំដែរ។ខ្ញុំនិយាយនឹងនាងនោះថា"ខ្ញុំតែងសួរដល់នារីជាច្រើននាក់ពីមូលហេតុ ដែលនាងពាក់ឈើឆ្កាងនៅនឹងត្រចៀក។ នារីម្នាក់ៗមានមូលហេតុល្អរៀងៗខ្លួន។ ខ្ញុំចង់ ដឹងថាតើហេតុអ្វីបានជានាងពាក់ក្រវិលឈើឆ្កាងនឹងគេដែរ?"នាងមានឫកត្រអឹតក្រទមណាស់។ នាងមើលមកខ្ញុំទំនងជាវិនិច្ឆ័យក្នុងចិត្តថា "តាទំពែកវែកដួងទៅលក់នេះ ចង់ញ៉ែអញទេដឹង?"



Page **7** of **13**

ក្រោយពីសម្លឹងខ្ញុំចង់ស៊ីសាច់នាងក៏បាញ់សរសម្ដីយ៉ាងមុតហើយស្រួយស្រែកយ៉ាងខ្លាំងថា "មកពីខ្ញុំជឿព្រះយេស៊ូវ ណាស់៖" ខ្ញុំស្រងាកចិត្តយ៉ាងខ្លាំងដោយឮសម្ដីគ្រីស្ទបរិស័ទមួយរូបបន្សល់ស្នាមទីបន្ទាល់ច្រាស់ឆ្អេះបែបនេះនៅទីសាធារណៈ។ប្រឈមមុខនឹងស្ថានការណ៍បែបនោះនាងពីរនាក់ទៀតដែលត្រូវជាមិត្តរបស់នាងពន្យល់ខ្ញុំដោយសុភាពថា "ពួកម៉ាកខ្ញុំវាជឿ យេស៊ូវ៖" មិត្តនាងប្រាប់ខ្ញុំដោយគោរពថាមិត្តនាងទៅវិហារមួយដែលខ្ញុំស្គាល់ដែរ។ ឯមិត្តរបស់នាងជាអ្នកគ្រីស្ទាននោះសុទ្ធតែជាអ្នកមិនជឿទេ។ លោកអ្នកបងប្អូនទាំងឡាយអើយបើនាងម្នាក់នោះពិតជាអ្នកគ្រីស្ទានមែនការដែលនាងបញ្ចោញសម្ដីគ្រោធ គ្រោតឆ្លើយនឹងមនុស្សទូទៅបែបនេះ មិនមែនជាទីបន្ទាល់សម្រាប់បន្សល់ទុកអោយអ្នកដ៏ទៃស្គាល់ព្រះនោះទេ។ខ្ញុំសូមជំរាបដល់លោកអ្នកបងប្អូនយ៉ាងដូច្នេះថាលោកអ័ប្រាហាំមិនបន្សល់ទុកបន្ទាល់បែបនាងស្រីម្នាក់នេះធ្វើទេ ប៉ុន្តែ គឺលោកបានថ្វាយបង្គំ ព្រះដោយចិត្តសុភាពរាបសារ ហើយមិនយូរប៉ុន្មានសាសន៍កាណានដឹងថាលោកជាមនុស្សម្នាក់ដែលថ្វាយបង្គំព្រះជាម្ចាស់តែមួយអង្គគត់ប៉ុណ្ណោះ។

### អាប់រ៉ាមក៏ចេះតែដើរដំណើរទៅឯត្បូងទៀត (លោកុ.១២:៩)។

លោកធ្វើដំណើរឆ្ពោះទៅស្រុកត្បូង។ជើងលោកចេះតែរមាស់ហើយលោកចេះតែរើកញ្ជើដើរឆ្ពោះទៅទិសខាងត្បូង។ មកទល់នឹងពេលនេះ លោកជួបឧបសគ្គធំ នៅក្នុងជីវិតរបស់ផងលោក ពោលគឺជាឧបសគ្គទីពីរ។

### អ័ប្រាហាំខ្វះជំនឿ

**នៅស្រុកនោះ កើតមានអំណត់អត់ហើយអាប់រ៉ាមចុះទៅសំណាក់ នៅឯស្រុកអេស៊ីព្ទវិញ ដ្បិតអំណត់នៅស្រុកកាណានបានខ្លាំង ណាស់ (លោកុ.១២:១០)។**



Page **8** of **13**

ឥឡូវអ័ប្រាហាំ បានមកដល់ទឹកដីដែលព្រះជាម្ចាស់សន្យាថា នឹងប្រគល់ជូន លោកហើយ។ ជាទឹកដីដែលពោរពេញទៅដោយព្រះពរហើយព្រះជាម្ចាស់មិនមានបំណងចង់អោយគាត់ចាកចេញពីទឹកដីនេះទេ។ប៉ុន្តែនៅក្នុងស្រុកដែលលោកកំពុងរស់នៅនេះកើតមានទុរ្ភិក្សហើយនៅព្រឹកមួយនោះលោកបានគិតជាមួយនឹងភរិយារួចហើយនិយាយទៅកាន់ប្រពន្ធលោកថា"សារ៉ាយមើលទៅគេទាំងអស់គ្នាធ្វើដំណើរ ទៅស្រុកអេស៊ីព្ទហើយ ពីព្រោះទុរ្ភិក្សនេះមានកំរិតកាន់តែខ្លាំងឡើងៗ។ ដូច្នេះយើងត្រូវធ្វើដំណើរចុះទៅជាមួយគេ"។ខ្ញុំគិតថានាងសារ៉ាយក៏យល់ស្របនឹងប្ដីក៏និយាយថា"ទីណាដែលលោកសម្រេចថានឹងទៅ ខ្ញុំជាប្រពន្ធរបស់លោក ក៏ទៅជាមួយលោក ជានិច្ច"។ លុះបានប៉ុន្មានថ្ងៃមកលោកក៏មានពួមនុស្សខ្លះធ្វើដំណើរចេញពីស្រុកខាងជើងប្រហែលមកពីតំបន់ដែលលោករស់នៅពីដើមនោះបានធ្វើដំណើរមកស្រុកត្បូងនេះដែរហើយបានប្រាប់លោកថានៅខាងជើងនេះក៏អត់បាយណាស់ដែរ។ នៅល្ងាច មួយនោះលោកក៏មាន ប្រសាសន៍ទៅកាន់ប្រពន្ធលោកថា ឥឡូវគ្មានផ្លូវជ្រើសរើសទេសូម យើងធ្វើដំណើរឆ្ពោះទៅទិសខាងលិច ពោលគឺឆ្ពោះទៅឯប្រទេសអេស៊ីព្ទ។ ដូច្នេះ អ័ប្រាហាំនិងសារ៉ាយគាត់ធ្វើដំណើរឆ្ពោះទៅប្រទេសអេស៊ីព្ទ។

ខ្ញុំសូមអោយលោកអ្នកកត់ចំណាំថាព្រះជាម្ចាស់មិនបានមានបន្ទូលអោយលោកអ័ប្រាហាំធ្វើយ៉ាងដូច្នេះទេ។ ពេលដែលព្រះជាម្ចាស់ទ្រង់បើកសម្តែងអោយលោក ឃើញក្នុងពេលចុងក្រោយបង្អស់ព្រះជាម្ចាស់ទ្រង់មានបន្ទូលថា "អ័ប្រាហាំ នេះជាដីជា ស្រុកដែលអញនឹងអោយទៅឯងនៅទីនេះឯងនឹងបានពរហើយអញនឹងប្រទានពរដល់ឯងនៅក្នុងស្រុកនេះ"។ប៉ុន្តែលោកអ្នកឃើញស្រាប់ហើយថា ត្រង់ចំណុចមួយនេះ លោកអ័ប្រាហាំមិនបានជឿដល់ព្រះបន្ទូលសន្យានោះទេបានជាលោកធ្វើដំណើរចុះទៅទឹកដីអេស៊ីព្ទវិញ។ នៅក្នុងព្រះគម្ពីរ ទឹកដីអេស៊ីព្ទជារូបភាពនៃលោកកីយ៍ហើយរូបភាព នេះ តែងតែទាស់ទទឹងជាមួយព្រះជានិច្ច នៅក្នុងព្រះគម្ពីរទាំងមូល។ សព្វថ្ងៃនេះអេស៊ីព្ទ



Page 9 of 13

នៅតែជាកន្លែងរបស់លោកីយ៍ដដែលមិនខុសពីសម័យនោះឡើយ។ប៉ុន្តែទោះកន្លែងនោះជាលោកីយ៍ក៏ដោយ លោកអ័ប្រាហាំសុខចិត្តធ្វើដំណើរចុះទៅអេស៊ីព្ទ។

លោកអ្នកបងប្អូនអើយ សព្វថ្ងៃនេះ លោកីយ៍កំពុងអូសទាញគ្រីស្ទបរិស័ទយ៉ាង ខ្លាំង។ គ្រីស្ទបរិស័ទភាគច្រើនយល់ដឹងពីហេតុការណ៍ជាក់ស្តែងនេះ។ ប៉ុន្តែគ្រីស្ទ បរិស័ទតែងនិយាយថា លោកគ្រូអើយខ្ញុំមិនអាចទៅថ្វាយបង្គំព្រះអង្គនៅយប់ថ្ងៃអាទិត្យបានទេពីព្រោះថ្ងៃស្អែកខ្ញុំត្រូវងើបទៅធ្វើការពីព្រលឹមផង។ ប៉ុន្តែតើមាននរណាម្នាក់ ដែលមិនទៅធ្វើការ? ខ្ញុំឆ្ងល់ណាស់ថា ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ គ្រីស្ទបរិស័ទច្រើន ណាស់ដែលទៅមើលល្ខោន ខ្លះក៏ដើរលេងទៅនេះទៅនោះ ខ្លះក៏អង្គុយមើលកុនភាគរហូតដល់យប់ជ្រៅហើយព្រឹកឡើងងើបទៅធ្វើការទាន់ដូចតែគ្នា។ហេតុអ្វីបានជា គ្រីស្ទបរិស័ទភាគច្រើនយកលេសថាគេមិនអាចទៅថ្វាយបង្គំព្រះអង្គនៅពេលយប់ថ្ងៃអាទិត្យពីព្រោះគេខ្លាចខកខានទៅធ្វើការនៅថ្ងៃស្អែក?ចំណុចនេះរឹតតែសបញ្ជាក់អោយកាន់តែច្បាស់ឡើងថាលោកីយ៍សព្វថ្ងៃកំពុងអូសទាញគ្រីស្ទបរិស័ទយ៉ាងប្រទាញប្រទង់ខ្លាំងណាស់។ឥឡូវយើងបែរមកបន្តដំណើររឿងលោកអ័ប្រាហាំទៅទៀត។ឧបមាថា លោកអ្នកបងប្អូនផ្ទាល់ធ្វើដំណើរទៅស្រាប់តែជួបលោកអ័ប្រាហាំ ដែលកំពុងតែនាំសាច់ញាតិនិងហ្វូងសត្វឆ្ពោះទៅកាន់ប្រទេសអេស៊ីព្ទ។ លោកអ្នកប្រហែលជាសួរលោក អ័ប្រាហាំថា "លោកអ៊ំអ័ប្រាហាំកំពុងតែធ្វើដំណើរខុសទិសហើយពីព្រោះលោកអ៊ំត្រូវតែនៅក្នុងស្រុកដែលព្រះជាម្ចាស់ប្រទានអោយ"។ ខ្ញុំជឿថាលោកអ័ប្រាហាំពិតជា មានមូលហេតុសមរម្យយ៉ាងអស្ចារ្យដើម្បីឆ្លើយតបជាមួយនឹងលោកអ្នកវិញ។លោក ប្រហែលជាឆ្លើយថា "កុំអីខ្ញុំមិនធ្វើដំណើរទៅអេស៊ីព្ទទេ ប៉ុន្តែមើលចុះគោខ្ញុំវាស្គមៗអស់ហើយហើយដោយសារនៅទីនោះមានស្មៅខ្ចីច្រើនខ្ញុំត្រូវនាំគោខ្ញុំទៅអោយស៊ី មួយរយៈពេលទំរាំដល់មានស្មៅបរិបូរនៅក្នុងស្រុកយើងនេះវិញ"។ រួចហើយលោកធ្វើដំណើរចុះទៅនៅទីនោះទាំងមិនស្តាប់បង្គាប់ព្រះដោយសុវត្ថិភាព។



Page **10** of **13**

ប៉ុន្តែមិនយូរប៉ុន្មានក្រោយដែលលោកបានទៅដល់ ក៏មានវិបត្តិមួយកើតឡើង ដល់រូបលោក។ វិបត្តិនោះទាក់ទងទៅនឹងប្រពន្ធរបស់លោកគឺសារ៉ាយពីព្រោះសារ៉ាយមានរូបឆោមលោមពណ៌ល្អណាស់។

**កាលគាត់ជិតចូលទៅក្នុងស្រុកអេស៊ីព្ទហើយ នោះគាត់និយាយ ទៅសារ៉ាយជាប្រពន្ធថាមើល អញដឹងថា ឯង នោះ ក្រែងគេ នឹងនិយាយពីឫងថាជាប្រពន្ធអញរួចគេនឹងសំឡាប់អញទៅ ហើយទុកឯងអោយពីឯងថាជាប្រពន្ធអញនោះក្រែងគេនិងនិយាយ ពីឯងថាជាប្រពន្ធអញ រួចគេនិងនិយាយពីឯង ថាជាប្រពន្ធអញ រួចគេ នឹងសំឡាប់អញទៅ ហើយទុកឯងអោយរស់នៅវិញ(លោកុប្បត្តិ១២៖១១-១២)។**

តើហេតុការណ៍រៀបរាប់ខាងលើ  មានឯកសារណាផ្សេងពីព្រះគម្ពីរ និយាយពីដំណើរលោកអ័ប្រាហាំចុះទៅប្រទេសអេស៊ីព្ទដែរឬទេ? លោកអ្នកបងប្អូន ខ្លះប្រហែលបានជ្រាបហើយថា មានគេរកឃើញក្រាំងនៅក្នុងរូងភ្នំមួយនៅទិសពាយ័ព្យនៃសមុទ្រស្លាប់។ក្រោយពីបានរកឃើញក្រាំងនោះមកមានអ្នកប្រាជ្ញជាច្រើនសប្បាយចិត្តពីព្រោះគិតគេថាមានភ័ស្តុតាងបន្ថែមទៀតយកមកប្រើជាឯកសារដើម្បី ធ្វើការបដិសេធហេតុការណ៍ដែលកើតឡើងក្នុងព្រះគម្ពីរ។ ប៉ុន្តែគេមិនអាចរកភ័ស្តុតាងផ្សេងទៀតដើម្បីយកមកបដិសេធព្រះគម្ពីរឡើយ។ផ្ទុយទៅវិញក្នុងក្រាំងទាំងនោះគេបានរកឃើញអត្ថបទបកស្រាយព្រះគម្ពីរ លោកុប្បត្តិ១២-១៥។ នៅក្នុងសេចក្ដីបកស្រាយទាំងនោះមានពីរជំពូកដែលឃើញមានអត្ថបទពណ៌នាពីសម្រស់ឆើតឆាយរបស់នាងសារ៉ាយ។ អត្ថបទនេះ គាំទ្រ ហេតុការណ៍


Page 11 of 13

ដែលកើតឡើងក្នុងព្រះគម្ពីរដោយឥតកែប្រកែកបាន។មិនតែប៉ុណ្ណោះ ក្រាំងនោះក៏បានពណ៌នាអំពីដំណើរត្រាច់ចរ ដែលបានថែង នៅក្នុងព្រះគម្ពីរលោកុប្បត្តិ១៣:១៧ ដែលថែងយ៉ាងដូច្នេះថា“ចូរឯងក្រោកហើយដើរចុះឡើងក្នុងស្រុកនេះតាមបណ្តោយនិងទទឹងចុះដ្បិតអញនឹងអោយដល់ឯង ហើយ”។ក្រាំងនោះក៏បញ្ជាក់ដែរថាដីធ្លីនៅកាណានមានជីវជាតិខ្លាំងណាស់។ប៉ុន្តែសព្វថ្ងៃនេះពេលដែលមនុស្សជាច្រើនដើរទៅឃើញដីនោះមិនគួរជឿថា ជាដី ដែលពោរពេញទៅដោយទឹកដោះហើយនិងទឹកឃ្មុំសោះ។ បទគម្ពីរចោទិយកថា បានបញ្ជាក់ថាហេតុអ្វីបានជាដីនោះ ផ្លាស់ប្រែពីសភាពមានជីវជាតិល្អ មកជាមានភាព សោះកក្រោះយ៉ាងដូច្នេះវិញ។ ប៉ុន្តែបើទោះជាយ៉ាងណាក៏ដោយក៏សម័យលោកអ័ប្រាហាំដីទីនោះមានជីវជាតិខ្លាំងណាស់។ទឹកដីនោះមានជីវជាតិក៏ពិតមែនប៉ុន្តែពេលមួយក្នុងប្រវត្តិសាស្រ្តមនុស្សលោកមានកើតទុរ្ភិក្សនៅទីនោះជាប្រាកដ។ការរាំងស្ងួតនោះបណ្តាលអោយលោក អ័ប្រាហាំនាំគ្រួសារ និងហ្វូងសត្វរបស់លោកធ្វើដំណើរចុះទៅប្រទេសអេស៊ីព្ទស្នាក់នៅទីនោះមួយរយៈពេលយ៉ាងយូរ។

**-ភ្លេងចំរៀង-**

**ពិធីករប្រុស១៖**កម្មវិធីនេះផលិតឡើងដោយវិទ្យុត្រែនវើល៍សហាការជាមួយThrough The Bible Network សូមលោកអ្នកបន្ត បើកស្តាប់កម្មវិធីនេះបន្តទៅទៀតចាប់ពីថ្ងៃចន្ទ័ដល់ថ្ងៃសុក្រដែលមានលោកគ្រូគង្វាល ជាគ្រូអធិប្បាយប្រចាំប្រពន្ធ័សិក្សាព្រះគម្ពីររបស់យើង។

**ពិធីករប្រុស២៖**កម្មវិធីនេះសហាការជាមួយនិងកម្មវិធីជីវិតបរិសុទ្ធឬក៏ទូរសព្វ័មកកាន់ការិល័យយើងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃចន្ទ័ដល់សុក្របូលេខទូរសព្វ័០១២៧៥៨៦៧៨៧៨ អ៊ីម៉ែល Adress TWR@TWR.org

សូមអរគុណសូមជំរាបលា។

**-ភ្លេងចប់----**


Page **12** of **13**

Page **13** of **13**